# ព្រះរាជក្រម

នស/រកម/០១២១/០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភា លើកទី៥ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសថាស្របនឹងធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ២១៣/០១៣/២០២០ កបធ.ច ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់

# ស្ដីពី

# ការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរ សេវាហិរញ្ញវត្ថុមិនមែនធនាគារ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សរសេរជាអក្សរកាត់ថា **អ.ស.ហ.** ដែលមានឯករាជ្យភាពក្នុងការបំពេញមុខងាររបស់ខ្លួន ដោយធ្វើសមាហរណកម្មយន្តការនៃការគ្រប់គ្រងនិងត្រួតពិនិត្យលើវិស័យហិរញ្ញវត្ថុមិនមែនធនាគារ មានជាអាទិ៍ វិស័យធានារ៉ាប់រងនិងសោធននឯកជន វិស័យមូលបត្រ វិស័យសន្តិសុខសង្គម វិស័យបរធនបាលកិច្ច វិស័យគណនេយ្យនិងសវនកម្ម និងវិស័យអចលនវត្ថុ វិស័យបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ក្នុងគោលបំណងពង្រឹងនិងធានាប្រសិទ្ធភាពនៃការគ្រប់គ្រង ការត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមទាំងការលើកកម្ពស់ការអភិវឌ្ឍនិងប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុលើវិស័យហិរញ្ញវត្ថុមិនមែនធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការនៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## បេសកកម្ម តួនាទី និងភារកិច្ច

**មាត្រា៣ .-**

សមត្ថកិច្ចជាបញ្ញត្តិកររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ព្រមទាំងសមត្ថកិច្ចជាបញ្ញត្តិកររបស់គណៈកម្មការមូលបត្រកម្ពុជា និងសមត្ថកិច្ចជាបញ្ញត្តិកររបស់ក្រុមប្រឹក្សាជាតិគណនេយ្យ ដូចមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ត្រូវបានផ្ទេរឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ **អ.ស.ហ.**។

**មាត្រា៤ .-**

**អ.ស.ហ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ជាបញ្ញត្តិករសម្រាប់វិស័យធានារ៉ាប់រងនិងសោធននឯកជន វិស័យមូលបត្រ វិស័យសន្តិសុខសង្គម វិស័យបរធនបាលកិច្ច វិស័យគណនេយ្យនិងសវនកម្ម និងវិស័យអចលនវត្ថុ វិស័យបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ដែលការអនុវត្តតួនាទីរបស់ **អ.ស.ហ.** នៅក្នុងវិស័យនីមួយៗ ត្រូវកំណត់នៅក្នុងជំពូកទី៣ ផ្នែកទី៣ ផ្នែកទី៤ ផ្នែកទី៥ ផ្នែកទី៦ ផ្នែកទី៧ និងផ្នែកទី៨នៃច្បាប់នេះ
- លើកសំណើអំពីគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមទាំងបច្ចេកវិទ្យាហិរញ្ញវត្ថុមិនមែនធនាគារជូនរាជរដ្ឋាភិបាល
- កំណត់ ត្រួតពិនិត្យ និងតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

- ពង្រឹងទំនុកចិត្តទីផ្សារ គាំពារវិនិយោគិន និងទប់ស្កាត់ឧក្រិដ្ឋកម្មហិរញ្ញវត្ថុនៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ តាមរយៈការចាត់ឱ្យមានការស៊ើបអង្កេត ប្រមូលព័ត៌មានពីគ្រប់បុគ្គលស្ថាប័នពាក់ព័ន្ធ និងអាចចាត់វិធានការបង្កកទ្រព្យសម្បត្តិឬសាច់ប្រាក់ក្នុងគណនីធនាគាររបស់បុគ្គលពាក់ព័ន្ធក្នុងករណីសង្ស័យប្រព្រឹត្តអំពើល្មើសក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដោយអនុវត្តស្របតាមច្បាប់ជាធរមាន
- រួមចំណែករក្សានិងពង្រឹងស្ថិរភាពហិរញ្ញវត្ថុ
- ជំរុញការអភិវឌ្ឍនវានុវត្តន៍ហិរញ្ញវត្ថុ។

## ជំពូកទី៣
## ការគ្រប់គ្រងនិងរចនាសម្ព័ន្ធ
### ផ្នែកទី១
### ក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

**មាត្រា៥ .-**

**អ.ស.ហ.** ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលតទៅនេះហៅកាត់ថា ក្រុមប្រឹក្សា។

**មាត្រា៦ .-**

ក្រុមប្រឹក្សាមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | អនុប្រធាន |
| ៣. | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| ៤. | តំណាងធនាគារជាតិនៃកម្ពុជា ១រូប | សមាជិក |
| ៥. | តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី ១រូប | សមាជិក |
| ៦. | តំណាងក្រសួងពាណិជ្ជកម្ម ១រូប | សមាជិក |
| ៧. | តំណាងក្រសួងយុត្តិធម៌ ១រូប | សមាជិក |
| ៨. | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** | សមាជិក |
| ៩. | អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា | សមាជិក |
| ១០. | អគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា | សមាជិក |
| ១១. | អគ្គនាយកនៃនិយ័តករសន្តិសុខសង្គម | សមាជិក |
| ១២. | អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច | សមាជិក |
| ១៣. | អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម | សមាជិក |
| ១៤. | អគ្គនាយកនៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ | សមាជិក |
| ១៥. | អ្នកជំនាញអព្យាក្រឹតដែលស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ៣រូប | សមាជិក។ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៧ .-**

ការកំណត់សមាសភាពជាក់ស្តែងនៃក្រុមប្រឹក្សាត្រូវធ្វើឡើងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា។ អនុប្រធាននិងសមាជិករបស់ក្រុមប្រឹក្សាជាតំណាងក្រសួងស្ថាប័ន ដូចកំណត់ក្នុងមាត្រា៦ ខាងលើ ត្រូវមានឋានៈនិងតួនាទីជារដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ឬអនុប្រធានស្ថាប័នឡើងទៅ។

អនុប្រធាននិងសមាជិករបស់ក្រុមប្រឹក្សាមានអាណត្តិចំនួន៥(ប្រាំ)ឆ្នាំ។ ក្នុងរយៈពេលនៃការបំពេញមុខងាររបស់ខ្លួន អនុប្រធាននិងសមាជិកអាចត្រូវបានដកហូតតំណែងឬផ្លាស់ប្តូរជំនួស។ អនុប្រធាន និងសមាជិកក្រុមប្រឹក្សា អាចត្រូវបានតែងតាំងសាជាថ្មីតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា នៅពេលផុតអាណត្តិ។

ក្រុមប្រឹក្សាអាចបង្កើតគណៈកម្មការជំនាញតាមការចាំបាច់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សា។

**មាត្រា៨ .-**

ក្រុមប្រឹក្សាមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ និងស្នើឡើងនូវគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមទាំងបច្ចេកវិទ្យាហិរញ្ញវត្ថុសម្រាប់វិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- ដាក់ចេញនូវផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- ពិនិត្យ និងតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពរបស់ **អ.ស.ហ.**
- ពិនិត្យនិងសម្រេចលើការរៀបចំប្រកាស សារាចរ និងសេចក្តីណែនាំផ្សេងៗ ដើម្បីគ្រប់គ្រងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- ពិនិត្យនិងសម្រេចលើលក្ខខណ្ឌ នីតិវិធី និងវិធាន ដើម្បីផ្តល់ ព្យួរ និងដកហូតអាជ្ញាបណ្ណ និង/ឬ វិញ្ញាបនបត្រ ការអនុញ្ញាត ការទទួលស្គាល់ ការចុះបញ្ជី ក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- លើកកម្ពស់ការអនុវត្តនិងជំរុញដល់ការប្រតិបត្តិនិងអនុលោមភាពតាមបញ្ញត្តិនៃច្បាប់នេះ
- ត្រួតពិនិត្យការអនុវត្តតួនាទីនិងភារកិច្ចរបស់និយ័តករក្រោមឱវាទ
- ពិនិត្យនិងអនុម័តគម្រោងថវិកាសម្រាប់កិច្ចដំណើរការរបស់ **អ.ស.ហ.** និងរបស់និយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.**
- ពិនិត្យនិងសម្រេចបទបញ្ជាផ្ទៃក្នុងរបស់ **អ.ស.ហ.**។

**មាត្រា៩ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាត្រូវរាយការណ៍ជាប្រចាំអំពីសកម្មភាពការងារដែលផ្តោតលើគោលនយោបាយនិងយុទ្ធសាស្ត្រ ព្រមទាំងបញ្ហាប្រឈមនានា រួមទាំងស្ថានភាពហិរញ្ញវត្ថុ ជូនប្រមុខរាជរដ្ឋាភិបាល។

**មាត្រា១០ .-**

**អ.ស.ម.** ត្រូវមាននិមិត្តសញ្ញានិងត្រាសម្រាប់បំពេញភារកិច្ចរបស់ខ្លួន។

**មាត្រា១១ .-**

**អ.ស.ម.** មានអង្គភាពក្រោមឱវាទជាសេនាធិការដូចខាងក្រោមៈ

- អគ្គលេខាធិការដ្ឋាន
- និយ័តករធានារ៉ាប់រងកម្ពុជា
- និយ័តករមូលបត្រកម្ពុជា
- និយ័តករសន្តិសុខសង្គម
- និយ័តករបរធនបាលកិច្ច
- និយ័តករគណនេយ្យនិងសវនកម្ម
- និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ
- អង្គភាពសវនកម្មផ្ទៃក្នុង។

**មាត្រា១២ .-**

និយ័តករនីមួយៗនៃ **អ.ស.ម.** ត្រូវបំពេញមុខងារនិយ័តកម្មរបស់ខ្លួនតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

និយ័តករនីមួយៗនៃ **អ.ស.ម.** ត្រូវមានថវិកានិងត្រាដោយឡែកសម្រាប់អនុវត្តតួនាទីរបស់ខ្លួន។

និយ័តករសន្តិសុខសង្គមប្រើប្រាស់កញ្ចប់ថវិការួមជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីបំពេញតួនាទីប្រចាំថ្ងៃរបស់ខ្លួន។

អគ្គលេខាធិការដ្ឋាននិងនិយ័តករនីមួយៗនៃ **អ.ស.ម.** ត្រូវស្នើសុំការពិនិត្យនិងអនុម័តថវិកាប្រចាំឆ្នាំរបស់ខ្លួនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈក្រុមប្រឹក្សា។ ថវិកាប្រចាំឆ្នាំរបស់ **អ.ស.ម.** និងអង្គភាពក្រោមឱវាទ គឺជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខ័ណ្ឌនៃថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន និយ័តករនីមួយៗ និងអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ម.** ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៣ .-**

អគ្គលេខាធិការដ្ឋាននៃ **អ.ស.ម.** ត្រូវដឹកនាំដោយអគ្គលេខាធិការ១(មួយ)រូប អមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់។

និយ័តករនីមួយៗនៃ **អ.ស.ម.** ត្រូវដឹកនាំដោយអគ្គនាយក១(មួយ)រូប អមដោយអគ្គនាយករងមួយចំនួនតាមការចាំបាច់។

អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ម.** ត្រូវដឹកនាំដោយប្រធាន១(មួយ)រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

បេក្ខភាពអគ្គលេខាធិការ អគ្គនាយក អគ្គលេខាធិការរង អគ្គនាយករង និងប្រធាននិងអនុប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** ត្រូវជ្រើសរើសនិងស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជូនប្រមុខរាជរដ្ឋាភិបាល។

**ផ្នែកទី២**

**អគ្គលេខាធិការដ្ឋាននៃ អ.ស.ហ.**

**មាត្រា១៤ .-**

អគ្គលេខាធិការដ្ឋានបំពេញមុខងារជាសេនាធិការឱ្យ **អ.ស.ហ.**។

**ផ្នែកទី៣**

**និយ័តករធានារ៉ាប់រងកម្ពុជា**

**មាត្រា១៥ .-**

និយ័តករធានារ៉ាប់រងកម្ពុជា ត្រូវអនុវត្តសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានចែងក្នុងច្បាប់ស្ដីពីការធានារ៉ាប់រងដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យធានារ៉ាប់រង។

**ផ្នែកទី៤**

**និយ័តករមូលបត្រកម្ពុជា**

**មាត្រា១៦ .-**

គណៈកម្មការមូលបត្រកម្ពុជា ត្រូវបានប្រែក្លាយទៅជានិយ័តករមូលបត្រកម្ពុជា ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ និយ័តករមូលបត្រកម្ពុជាត្រូវអនុវត្តមុខងាររបស់គណៈកម្មការមូលបត្រកម្ពុជា ដូចមានចែងក្នុងច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជនដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យមូលបត្រ។

**មាត្រា១៧ .-**

អគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា ត្រូវអនុវត្តមុខងាររបស់អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ដូចមានចែងក្នុងច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យមូលបត្រ។

**ផ្នែកទី៥**

**និយ័តករសន្តិសុខសង្គម**

**មាត្រា១៨ .-**

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ត្រូវបំពេញតួនាទីបន្ថែមជានិយ័តករសន្តិសុខសង្គម ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ និយ័តករសន្តិសុខសង្គម ត្រូវអនុវត្តតួនាទីនិងភារកិច្ច ដូចមានចែងក្នុងច្បាប់ស្ដីពីរបបសន្តិសុខសង្គម ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/[illegible]០១៦ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យសន្តិសុខសង្គម។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា១៩ .-**

អគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម ត្រូវបំពេញតួនាទីនិងភារកិច្ចបន្ថែមជាអគ្គនាយកនៃនិយ័តករសន្តិសុខសង្គម។

## ផ្នែកទី៦

## និយ័តករបរធនបាលកិច្ច

**មាត្រា២០ .-**

និយ័តករបរធនបាលកិច្ច ត្រូវអនុវត្តសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានចែងក្នុងច្បាប់ស្ដីពីបរធនបាលកិច្ចដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យបរធនបាលកិច្ច។

## ផ្នែកទី៧

## និយ័តករគណនេយ្យនិងសវនកម្ម

**មាត្រា២១ .-**

ក្រុមប្រឹក្សាជាតិគណនេយ្យ ត្រូវបានប្រែក្លាយទៅជានិយ័តករគណនេយ្យនិងសវនកម្ម ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ និយ័តករគណនេយ្យនិងសវនកម្មត្រូវអនុវត្តមុខងារនិងភារកិច្ចរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ ដូចមានចែងក្នុងច្បាប់ស្ដីពីគណនេយ្យនិងសវនកម្មដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យគណនេយ្យនិងសវនកម្ម។

## ផ្នែកទី៨

## និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ

**មាត្រា២២ .-**

និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ ត្រូវអនុវត្តតួនាទីនិងភារកិច្ចដូចមានកំណត់នៅក្នុងមាត្រា៥ នៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យអចលនវត្ថុ វិស័យបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន។

## ជំពូកទី៤

## អន្តរប្បញ្ញត្តិ

**មាត្រា២៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលបាននិងកំពុងអនុវត្តពាក់ព័ន្ធនឹងវិស័យធានារ៉ាប់រងនិងសោធននិវត្តន៍ វិស័យមូលបត្រ វិស័យសន្តិសុខសង្គម វិស័យបរធនបាលកិច្ច វិស័យគណនេយ្យនិងសវនកម្ម និងវិស័យអចលនវត្ថុ វិស័យបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់ពេលមានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមច្បាប់នេះ។

**មាត្រា២៤ ._**

ដើម្បីធានានិរន្តរភាពការងារពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិគណនេយ្យ ត្រូវបំពេញមុខងារ តួនាទី ភារកិច្ច និងសមត្ថកិច្ច ដូចមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន រហូតដល់និយ័តករនីមួយៗនៃ **អ.ស.ហ.** ចាប់ផ្តើមបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួនស្របតាមលិខិតបទដ្ឋានគតិយុត្តតាមវិស័យដោយអនុលោមតាមច្បាប់នេះ។

គណៈកម្មការមូលបត្រកម្ពុជា ត្រូវបន្តការងារជាធម្មតារហូតដល់មានការរៀបចំសមាសភាពរបស់ក្រុមប្រឹក្សាតាមការស្នើសុំរបស់ប្រធានក្រុមប្រឹក្សា។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា២៥ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ថ្ងៃ សៅរ៍ ៣កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០២១

នស/រកម.០១២១.០០៤

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**